ASIAN DEVELOPMENT BANK
6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines
Tel + 63 2 632 4444
Fax + 63 2 636 4444

www.adb.org

# សេចក្តីប្រកាសព័ត៌មាន

## របាយការណ៍ថ្មី៖ ការប្រែប្រួលអាកាសធាតុ នឹងធ្វើឱ្យការអភិវឌ្ឍន៍ នៅអាស៊ី ដើរត្រឡប់ថយក្រោយ

**ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន (ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧)** ៖ យោងតាមរបាយការណ៍មួយដែលរៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង វិទ្យាស្ថាន Potsdam សម្រាប់ការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ (PIK) ការប្រែប្រួលអាកាសធាតុដែលគ្មានការថមថយ នឹងបង្កឱ្យមានការបំផ្លិចបំផ្លាញចំពោះបណ្តាប្រទេសនានានៅតំបន់អាស៊ី និង ប៉ាស៊ីហ្វិក ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះកំណើនសេដ្ឋកិច្ចរបស់ពួកគេនៅពេលអនាគត ធ្វើឱ្យមាននិន្នាការត្រឡប់ថយក្រោយវិញចំពោះលទ្ធផលអភិវឌ្ឍន៍ដែលសម្រេចបាននាពេលបច្ចុប្បន្ន និង ធ្វើឱ្យថយចុះនូវគុណភាពជីវិតរស់នៅ។

ស្ថិតក្រោមស៊ីណារីយូជាប្រក្រតី គេបានព្យាករណ៍ថានឹងមានការកើនឡើងសីតុណ្ហភាព ៦ អង្សាសេ ក្នុងតំបន់អាស៊ី នៅដំណាច់សតវត្សរ៍នេះ។ យោងតាមរបាយការណ៍ដែលមានចំណងជើងថា "*តំបន់មួយដែលមានការប្រឈមៈ ទិដ្ឋភាពមនុស្សនៃការប្រែប្រួលអាកាសធាតុនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក*" បានឱ្យដឹងថា ប្រទេសមួយចំនួនក្នុងតំបន់អាចទទួលរងអាកាសធាតុដែលកាន់តែក្តៅជាងមុនគួរឱ្យកត់សម្គាល់ ដោយកំណើនសីតុណ្ហភាពនៅប្រទេសតាជីគីស្ថាន អាហ្គានីស្ថាន ប៉ាគីស្ថាន និង ភាគពាយ័ព្យនៃសាធារណរដ្ឋប្រជាមានិតចិន ត្រូវបានព្យាករណ៍ថានឹងកើនឡើង ៨ អង្សាសេ។

កំណើនសីតុណ្ហភាពទាំងនេះនឹងបណ្តាលឱ្យមានការប្រែប្រួលយ៉ាងគំហុក ចំពោះប្រព័ន្ធធាតុអាកាសក្នុងតំបន់ វិស័យកសិកម្ម និងជលផល ដី និង ជីវចម្រុះនៅក្នុងទឹក សន្តិសុខជាតិ និងតំបន់ ពាណិជ្ជកម្ម ការអភិវឌ្ឍន៍តំបន់ទីក្រុង ទេសន្តរប្រវេសន៍ និង សុខភាព។ ស៊ីណារីយូបែបនេះ ថែមទាំងអាចបង្កការគំរាមកំហែងដែលមានស្រាប់ទៅលើប្រទេសមួយចំនួនក្នុងតំបន់ទៀតផង ព្រមទាំងធ្វើឱ្យបាត់បង់ក្តីសង្ឃឹមក្នុងការសម្រេចបានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និង បរិយាប័ន។

Bambang Susantono អនុប្រធានធនាគារអភិវឌ្ឍន៍អាស៊ី ទទួលបន្ទុកការគ្រប់គ្រងចំណេះដឹង និង ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព បានមានប្រសាសន៍ឱ្យដឹងថា "វិបត្តិអាកាសធាតុសកល គឺជាបញ្ហាប្រឈមដ៏ធំបំផុតដែលមនុស្សកំពុងជួបប្រទះនៅក្នុងសតវត្សរ៍ទី២១ ដោយតំបន់អាស៊ី និងប៉ាស៊ីហ្វិក គឺជាចំនុចស្នូលនៃបញ្ហាទាំងអស់នេះ"។ "បណ្តាប្រទេសនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក គឺជាលំនៅដ្ឋានរបស់ជនក្រីក្រចំនួនពីរភាគបីនៅក្នុងពិភពលោក និងត្រូវបានចាត់ទុក

**Media Inquiries**

Harumi Kodama
Tel: (632) 632 5291
Mob: (63) 908 888 6701
Email: hkodama@adb.org

ថាជាតំបន់មួយដែលងាយរងគ្រោះបំផុតទៅនឹងការប្រែប្រួលអាកាសធាតុ។ បណ្ដាប្រទេសនៅអាស៊ី និង ប៉ាស៊ីហ្វិក មាន ការប្រឈមខ្ពស់បំផុតក្នុងការធ្លាក់ចូលទៅក្នុងភាពក្រីក្រកាន់តែជ្រាលជ្រៅ និង គ្រោះមហន្តរាយ ប្រសិនបើ កិច្ចខិតខំកាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មិនត្រូវបានអនុវត្តឱ្យបានឆាប់រហ័ស និង រឹងមាំទេនោះ។

សាស្ត្រាចារ្យ Hans Joachim Schellnhuber នាយក PIK បានមានប្រសាសន៍ឱ្យដឹងថា "បណ្ដាប្រទេសអាស៊ានគឺជាអ្នកគ្រប់គ្រងអនាគតរបស់ភពផែនដីនៅក្នុងដៃរបស់ពួកគេ។ ប្រសិនបើពួកគេជ្រើសរើសការពារខ្លួនឯងប្រឆាំងនឹងការប្រែប្រួលអាកាសធាតុដ៏គ្រោះថ្នាក់នេះ ពួកគេនឹងអាចជួយសង្គ្រោះភពផែនដីទាំងមូលបាន"។ "បញ្ហាប្រឈមមានពីរយ៉ាង។ ទីមួយ ការបំភាយឧស្ម័នផ្ទះកញ្ចក់នៅអាស៊ី ត្រូវតែកាត់បន្ថយក្នុងលក្ខណៈមួយដែលសហគមន៍សកលអាចដាក់កម្រិតបានទៅលើកំដៅបរិយាកាសភពផែនដីឱ្យស្ថិតក្រោម ២អង្សារសេ ដូចបានឯកភាពនៅទីក្រុងប៉ារីស ក្នុងឆ្នាំ ២០១៥។ ប៉ុន្តែ សូម្បីតែការបន្សាំទៅនឹងកំណើនសីតុណ្ហភាពចំនួន ១,៥អង្សារសេ គឺជាភារកិច្ចមួយដ៏ធំធេងទៅហើយ។ ដូច្នេះ បញ្ហាប្រឈមទីពីរគឺ បណ្ដាប្រទេសអាស៊ីត្រូវស្វែងរកយុទ្ធសាស្ត្រដើម្បីធានាឱ្យមានវិបុលភាព និងសន្តិសុខ ក្រោមបញ្ហាការប្រែប្រួលអាកាសធាតុដែលមិនអាចជៀសវាងបាន នៅក្នុងការអភិវឌ្ឍន៍សកលមួយដែលមានលក្ខណៈល្អប្រសើរ។ យ៉ាងណាមិញ គប្បីកត់សម្គាល់ថា ការដឹកនាំបដិវត្តន៍ឧស្សាហកម្មស្អាតមួយ នឹងផ្ដល់ឱ្យតំបន់អាស៊ីនូវកាលានុវត្តភាពសេដ្ឋកិច្ចដែលមិនធ្លាប់មានពីមុន។ ការស្វែងរកយុទ្ធសាស្ត្រល្អបំផុតដើម្បីស្រូបយកវិបត្តិនៃការប្រែប្រួលអាកាសធាតុ នឹងធ្វើឱ្យអាស៊ីក្លាយជាតួអង្គមួយដ៏សំខាន់នៅក្នុងពហុភាគីនិយម នាសតវត្សរ៍ទី២១។"

គេរំពឹងថានឹងមានព្យុះទីហ្វុន និង ព្យុះស៊ីក្លូនតំបន់ត្រូពិក បោកបក់លើតំបន់អាស៊ី និងប៉ាស៊ីហ្វិក ព្រមជាមួយនឹងកំណើនមធ្យមភាគសីតុណ្ហភាពសកល។ ស្ថិតក្រោមស៊ីណារីយ៉ូជាប្រក្រតី គេរំពឹងថាកំណកអាកាសប្រចាំឆ្នាំនឹងមានការកើនឡើងរហូតដល់ ៥០% លើផ្ទៃដីភាគច្រើនក្នុងតំបន់ លើកលែងតែប្រទេសប៉ាគីស្ថាន និង អាហ្គានីស្ថាន ដែលអាចទទួលរងការធ្លាក់ចុះនៃទឹកភ្លៀង ចន្លោះពី ២០%-៥០%។

តំបន់ឆ្នេរ និងតំបន់ទំនាប នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក នឹងមានហានិភ័យទឹកជំនន់កើនឡើង។ ទីក្រុងចំនួន ១៩ ក្នុងចំណោមទីក្រុងចំនួន២៥ ដែលប្រឈមខ្លាំងបំផុតទៅនឹងកំណើននីវ៉ូទឹកសមុទ្រចំនួន១ម៉ែត្រ ស្ថិតនៅក្នុងតំបន់នេះ ដោយក្នុងនោះមានទីក្រុងចំនួន៧ ស្ថិតនៅក្នុងប្រទេសហ្វីលីពីន។ បើទោះជាដូច្នេះក្តី ប្រទេសឥណ្ឌូនេស៊ី នឹងក្លាយជាប្រទេសដែលរងផលប៉ះពាល់ខ្លាំងបំផុតពីការជន់លិចតំបន់ឆ្នេរនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដោយរំពឹងថានឹងមានមនុស្សប្រមាណ ៥,៩លាននាក់ រងផលប៉ះពាល់រៀងរាល់ឆ្នាំ រហូតដល់ឆ្នាំ២១០០។

កំណើនភាពងាយរងគ្រោះទៅនឹងទឹកជំនន់ និង គ្រោះមហន្តរាយដទៃទៀត នឹងបង្កឱ្យមានផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ទៅលើតំបន់ និង ពិភពលោកទាំងមូល។ គេរំពឹងថា ការខាតបង់បណ្ដាលមកពីទឹកជំនន់សកលនឹងកើនឡើងរហូតដល់ ៥២ពាន់ លានដុល្លា ក្នុងមួយឆ្នាំ គិតត្រឹមឆ្នាំ ២០៥០ ដោយតម្លៃនៃការខាតបង់នេះមានចំនួន ចាប់ពី ៦ពាន់លានដុល្លា ក្នុងឆ្នាំ២០០៥។ លើសពីនេះទៀត ទីក្រុងចំនួន១៣ ក្នុងចំណោមទីក្រុងចំនួន២០ ដែលមានកំណើន

នៃការខាតបង់បណ្តាលពីទឹកជំនន់ច្រើនជាងគេបំផុត ពីឆ្នាំ២០០៥ រហូតដល់ឆ្នាំ២០៥០ ស្ថិតនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ហើយទីក្រុងទាំងនោះមានដូចជា៖ Guangzhou, Shenzhen, Tianjin, Zhanjiang និង Xiamen (ចិន); Mumbai, Chennai-Madras, Surat និង Kolkata (ឥណ្ឌា); Ho Chi Minh City (វៀតណាម); Jakarta (ឥណ្ឌូនេស៊ី); Bangkok (ថៃ); និង Nagoya (ជប៉ុន)។

ការប្រែប្រួលអាកាសធាតុ ក៏នឹងធ្វើឱ្យផលិតកម្មស្បៀងអាហារនៅក្នុងតំបន់កាន់តែមានការលំបាក និង ធ្វើឱ្យថ្លៃដើមផលិតខ្ពស់ជាងមុនផងដែរ។ នៅក្នុងប្រទេសមួយចំនួននៃតំបន់អាស៊ីអាគ្នេយ៍ ទិន្នផលស្រូវអាចធ្លាក់ចុះរហូតដល់ ៥០% ត្រឹមឆ្នាំ២១០០ ប្រសិនបើពុំមានកិច្ចខិតខំប្រឹងប្រែងបន្សាំណាមួយត្រូវបានធ្វើឡើងទេនោះ។ ស្របពេលជាមួយគ្នានេះ កសិផលស្ទើរតែគ្រប់ប្រភេទនៅ Uzbekistan ត្រូវបានព្យាករណ៍ថានឹងមានការធ្លាក់ចុះប្រមាណ ២០% ទៅ ៥០% ត្រឹមឆ្នាំ២០៥០ បើទោះបីសីតុណ្ហភាពមានការកើនឡើងត្រឹមកម្រិត២អង្សារសេ ក៏ដោយ (ស៊ីណារីយូកិច្ចព្រមព្រៀងទីក្រុងប៉ារីស)។ កង្វះស្បៀងអាហារអាចធ្វើឱ្យមានការកើនឡើងនូវចំនួនកុមារខ្វះអាហារូបត្ថម្ភនៅអាស៊ីខាងត្បូង ចំនួន ៧លាននាក់ អាស្រ័យដោយថ្លៃចំណាយលើការនាំចូលទំនិញនឹងមានការកើនឡើងនៅក្នុងអនុតំបន់ ពី ២៣ពាន់លានដុល្លា រហូតដល់ ១៥៣ពាន់លានដុល្លា នៅឆ្នាំ២០៥០។

ប្រព័ន្ធអេកូឡូស៊ីនៅក្នុងទឹក ជាពិសេសនៅតំបន់ប៉ាស៊ីហ្វិកខាងលិច នឹងមានគ្រោះថ្នាក់ធ្ងន់ធ្ងរ នៅឆ្នាំ២១០០។ រាល់ប្រព័ន្ធដំណុះផ្កាថ្មនៅក្នុងអនុតំបន់ នឹងខូចខាតដោយសារការបាត់បង់ពណ៌ដែលកើតឡើងក្នុងទ្រង់ទ្រាយធំ ប្រសិនបើកំដៅភពផែនដីមានការកើនឡើងត្រឹម ៤អង្សារសេ (ស៊ីណារីយូជាប្រក្រតីកម្រិតសកល)។ បើទោះបីកំណើនសីតុណ្ហភាពត្រឹម ១,៥អង្សារសេ ក៏ដោយ គេរំពឹងថាផ្កាថ្មចំនួន ៨៩% នឹងរងផលប៉ះពាល់ពីការបាត់បង់ពណ៌យ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលឱ្យប៉ះពាល់ធ្ងន់ធ្ងរបន្តទៀតដល់វិស័យជលផល និងទេសចរណ៍ទាក់ទងនឹងផ្កាថ្ម នៅអាស៊ីអាគ្នេយ៍។

ការប្រែប្រួលអាកាសធាតុ ក៏បង្កនូវហានិភ័យគួរឱ្យកត់សម្គាល់ចំពោះសុខភាពនៅតំបន់អាស៊ី និង ប៉ាស៊ីហ្វិកផងដែរ។ អ្វីដែលបានកើតឡើងរួចមកហើយនោះគឺ មានមនុស្ស ៣,៣លាននាក់ ស្លាប់ជារៀងរាល់ឆ្នាំដោយសារផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់នៃការបំពុលខ្យល់អាកាសនៅខាងក្រៅ ដោយក្នុងនោះមានប្រទេសចិន ឥណ្ឌា ប៉ាគីស្ថាន និង បង់ក្លាដេស ជាប្រទេសទាំង៤ដែលឈរនៅលំដាប់លេខរៀងខ្ពស់ជាងគេ ក្នុងការទទួលរងនូវការស្លាប់ដោយសារមូលហេតុនេះ។ បន្ថែមពីនេះទៀត យោងតាមទិន្នន័យពីអង្គការសុខភាពពិភពលោក គេរំពឹងថា ការស្លាប់នៅក្នុងចំណោមមនុស្សចាស់ដែលទាក់ទងនឹងកំដៅនៅក្នុងតំបន់ នឹងមានការកើនឡើងប្រមាណ ៥២.០០០ករណី នៅឆ្នាំ២០៥០ ដោយសារតែការប្រែប្រួលអាកាសធាតុ។ ការស្លាប់ដែលទាក់ទងនឹងជម្ងឺបង្កឡើងដោយភ្នាក់ងារចម្លងរោគ ដូចជាជម្ងឺគ្រុនចាញ់ និង ជម្ងឺគ្រុនឈាម ក៏អាចមានការកើនឡើងផងដែរ។

អភិក្រមស៊ីណារីយូជាប្រក្រតីមួយចំពោះការប្រែប្រួលអាកាសធាតុ ក៏អាចបង្កការរំខានដល់ដំណើរការប្រព្រឹត្តទៅនៃសេវាប្រព័ន្ធអេកូឡូស៊ីផងដែរ អាស្រ័យដោយវាបណ្តាលឱ្យមានការធ្វើទេសន្តរប្រវេសន៍ក្នុងទ្រង់ទ្រាយធំ ដែលភាគ

ច្រើនគឺជាការធ្វើទេសន្តរប្រវេសន៍ទៅតំបន់ទីក្រុង ព្រមទាំងនាំឱ្យទីក្រុងកាន់តែមានភាពកកកុញ និង សម្រុកប្រើប្រាស់សេវាសង្គមដែលមាន។

លើសពីនេះទៀត អាកាសធាតុដែលកាន់តែក្តៅនៅក្នុងតំបន់ អាចបង្កគ្រោះថ្នាក់ដល់ការផ្គត់ផ្គង់ថាមពល។ ការប្រែប្រួលអាកាសធាតុ អាចធ្វើឱ្យអស្ថេរភាពនៃការផ្គត់ផ្គង់ថាមពលកាន់តែមានភាពធ្ងន់ធ្ងរឡើង តាមរយៈការបន្តពឹងផ្អែកលើឥន្ធនៈហ្វូស៊ីលដែលគ្មាននិរន្តរភាព ការថយចុះនៃសមត្ថភាពរោងចក្រអគ្គិសនីចំហាយទឹក ដោយសារតែខ្សត់ទឹកត្រជាក់សម្រាប់ធ្វើប្រតិកម្មចំហាយទឹកផលិតអគ្គិសនី និង ការរអាក់រអួលក្នុងការបំពេញមុខងាររបស់រោងចក្រវារីអគ្គិសនីដោយសារតែទឹកគ្មានស្ថេរភាព ព្រមទាំងកត្តាជាច្រើនដទៃទៀត។ អស្ថេរភាពថាមពលក៏អាចនាំឱ្យមានជម្លោះផងដែរ អាស្រ័យដោយប្រទេសនានាអាចប្រជែងគ្នា ដើម្បីទទួលបានការផ្គត់ផ្គង់ថាមពលដ៏មានកម្រិត។

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ របាយការណ៍នេះបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការអនុវត្តការប្តេជ្ញាចិត្តដែលមានកំណត់នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ ការប្តេជ្ញាចិត្តទាំងនេះរួមមាន ការវិនិយោគសាធារណៈ និងឯកជន ដែលផ្តោតលើការកាត់បន្ថយកាបូនឱ្យបានឆាប់រហ័សពីសេដ្ឋកិច្ចអាស៊ី ព្រមទាំងការអនុវត្តវិធានការណ៍បន្សាំ ដើម្បីការពារប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុតនៅក្នុងតំបន់។ កិច្ចខិតខំកាត់បន្ថយផលប៉ះពាល់ និង បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក៏គួរបញ្ច្រៀបទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់កម្រិតម៉ាក្រូ និង ការរៀបចំគម្រោងកម្រិតមីក្រូ នៅក្នុងគ្រប់វិស័យផងដែរ បន្ថែមពីលើកិច្ចខិតខំពាក់ព័ន្ធនឹងថាមពលកកើតឡើងវិញ និង នវានុវត្តន៍បច្ចេកវិទ្យានៅក្នុងហេដ្ឋារចនាសម្ព័ន្ធ និងការដឹកជញ្ជូននៅតំបន់ទីក្រុង។ របាយការណ៍បានធ្វើការសន្និដ្ឋានថា តំបន់នេះមានទាំងសមត្ថភាព និងទម្ងន់នៃឥទ្ធិពល ដើម្បីបោះជំហានឆ្ពោះទៅរកមាគ៌ាអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព គ្រប់គ្រងទៅលើការបំភាយឧស្ម័ននៅកម្រិតសកល និង លើកកម្ពស់ការបន្សាំ។

ធនាគារអភិវឌ្ឍន៍អាស៊ី បានអនុម័តទៅលើកំណត់ហេតុថវិកាហិរញ្ញប្បទានអាកាសធាតុ ចំនួន ៣,៧ពាន់លានដុល្លា ក្នុងឆ្នាំ២០១៦ ព្រមទាំងបានប្តេជ្ញាបន្តពង្រីកការវិនិយោគរបស់ខ្លួនបន្ថែមទៀតរហូតដល់ ៦ពាន់លានដុល្លា នៅឆ្នាំ ២០២០។

មានមូលដ្ឋាននៅទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ីប្តេជ្ញាកាត់បន្ថយភាពក្រីក្រនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពផ្នែកបរិស្ថាន និងសមាហរណ-កម្មតំបន់។ បង្កើតឡើងក្នុងឆ្នាំ១៩៦៦ ធនាគារអភិវឌ្ឍន៍អាស៊ី កំពុងប្រារព្ធខួបលើកទី៥០ឆ្នាំ នៃភាពជាដៃគូអភិវឌ្ឍន៍របស់ខ្លួនក្នុងតំបន់។ ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាកម្មសិទ្ធរបស់សមាជិកចំនួន ៦៧ប្រទេស ក្នុងនោះមានប្រទេសចំនួន ៤៨ ស្ថិតនៅក្នុងតំបន់នេះ។ ក្នុងឆ្នាំ២០១៦ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយសរុបចំនួន ៣១,៧ពាន់លានដុល្លារ ក្នុងនោះរួមមាន ១៤ពាន់លានដុល្លារ ជាសហហិរញ្ញប្បទាន។